ធនាគារជាតិ នៃ កម្ពុជា

លេខ...ធ១៣.០២០.១១៨សជណ......

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

*ថ្ងៃព្រហស្បតិ៍ ៥ រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣*

*រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០*

## សេចក្តីជូនដំណឹង
## ស្តីពី លទ្ធផលនៃកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ លើកទី៥០

នៅថ្ងៃព្រហស្បតិ៍ ៥ រោច ខែផល្គុន ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ៣:០០ រសៀល ធនាគារជាតិនៃកម្ពុជាបានរៀបចំកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុលើកទី៥០ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ទេសាភិបាល និងជាប្រធានគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ។ អង្គប្រជុំបានពិភាក្សាលើបច្ចុប្បន្នភាពនៃស្ថានភាពសេដ្ឋកិច្ចពិភពលោក វឌ្ឍនភាព និងបញ្ហាប្រឈមនៃស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា ព្រមទាំងគោលនយោបាយរូបិយវត្ថុសម្រាប់អនុវត្តនាគ្រាខាងមុខ។

ដើម្បីបន្តរក្សាស្ថិរភាពថ្លៃ សំដៅរួមចំណែកគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ បានសម្រេចបន្តអនុវត្តគោលនយោបាយរូបិយវត្ថុ ដូចខាងក្រោម ៖

១/- បន្តរក្សាស្ថិរភាពអត្រាប្តូរប្រាក់ តាមរយៈការធ្វើអន្តរាគមន៍សមស្រប ផ្អែកលើស្ថានភាពសេដ្ឋកិច្ច

២/- បន្តរក្សាការផ្គត់ផ្គង់សន្ទនីយភាពជាប្រាក់រៀលតាមរយៈប្រតិបត្តិការ LPCO

៣/- ពន្លឿនការអភិវឌ្ឍទីផ្សារប្តូរប្រាក់ សម្រាប់គាំទ្រការប្រើប្រាស់ប្រាក់រៀល

៤/- បន្តផ្សព្វផ្សាយការយល់ដឹងពីប្រាក់រៀល និងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយ

៥/- បន្តអនុវត្តប្រកាសស្តីពី ការផ្តល់ឥណទានជារូបិយវត្ថុជាតិយ៉ាងតិច ១០% នៃឥណទានសរុប និង

៦/- ដាក់ឱ្យប្រើប្រាស់ការផ្តល់សន្ទនីយភាពរយៈពេលខ្លី (MLF) នៅក្នុងត្រីមាសទី១ ឆ្នាំ ២០២០។

**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**
**ប្រធានគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ**

ជា_ចាន់តូ

**ចម្លងជូន ៖**
- សមាជិកគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ
- ឯកសារ-កាលប្បវត្តិ